ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៩ លេខ ០២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



Work Activities

ប្រចាំខែកុម្ភៈ ឆ្នាំ២០១៦



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្ដីព្រាងច្បាប់ស្ដីពីការដឹកជញ្ជូនតាមផ្លូវទឹក | ១ |
| ២- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ៣ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកុម្ភៈ ឆ្នាំ២០១៦ | ៦ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៤ |

## សេចក្តីព្រាងច្បាប់ស្តីពី

# ការដឹកជញ្ជូនតាមផ្លូវទឹក

ឯកឧត្តម **លី គឹមសុខ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ បានដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក** ជាច្រើនលើក ហើយបានបញ្ចប់នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦។ អង្គប្រជុំនេះមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋ មន្ត្រី និងតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។




ព្រះរាជាណាចក្រកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បាននឹងកំពុងរីកចម្រើនលើគ្រប់វិស័យ ជាពិសេសការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចបានកំណត់នៅក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សំដៅបន្តបង្កើនការស្តារ ការសាងសង់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនប្រកបដោយគុណភាព សម្រាប់បម្រើឲ្យការដឹកជញ្ជូនពហុរូបភាព គឺទាំងដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងការដឹកជញ្ជូនតាមផ្លូវអាកាស ដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស តភ្ជាប់ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីធានាការធ្វើដំណើរទៅគ្រប់ច្រកល្ហក និងការផ្តល់សេវាដឹកជញ្ជូនបានគ្រប់គ្រាន់ គ្រប់រដូវកាលប្រកបដោយផាសុខភាព សណ្តាប់ធ្នាប់ ប្រកបដោយប្រសិទ្ធភាព និងមានតម្លៃទាប ជាកំលាំងចលករដ៏មានសារៈសំខាន់ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ។

ការដឹកជញ្ជូនតាមផ្លូវទឹក ជាផ្នែកមួយមានសារៈសំខាន់ដែលបានរួមចំណែកក្នុងការលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសម្រួលដល់ការដឹកជញ្ជូនទំនិញ អ្នកដំណើរ សម្រាប់បម្រើឲ្យវិស័យពាណិជ្ជកម្ម កសិឧស្សាហកម្ម និងទេសចរណ៍ ព្រមទាំងផ្តល់ឱកាសដល់អ្នកវិនិយោគទុនជាតិនិងអន្តរជាតិ។ ប្រតិបត្តិការ

ដឹកជញ្ជូនតាមផ្លូវទឹកបានផ្ដល់ការងារជាច្រើននិងជួយសម្រួលដល់ការរស់នៅរបស់ប្រជាជនតាមផ្លូវទឹកជាអាទិ៍ ទន្លេ ស្ទឹង បឹង ព្រែក ប្រឡាយ និងឆ្នេរសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា។

ផ្អែកលើមូលដ្ឋានដូចបានរៀបរាប់ខាងលើ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រោមការណែនាំចង្អុលបង្ហាញរបស់រាជរដ្ឋាភិបាល បានខិតខំអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងរៀបចំលិខិតបទដ្ឋានគតិយុត្ត ដែលជាតម្រូវការចាំបាច់សម្រាប់ដាក់ចេញជាយន្តការ និងវិធានការនានាក្នុងគោលបំណង និងគោលដៅគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក រក្សាសណ្ដាប់ធ្នាប់ សុវត្ថិភាព និងសន្តិសុខក្នុងការធ្វើនាវាចរណ៍ ការពារអាយុជីវិតមនុស្ស សត្វ ទប់ស្កាត់ការខូចខាតទ្រព្យសម្បត្តិរដ្ឋ និងឯកជន រួមចំណែកការពារផលប៉ះពាល់បរិស្ថានតាមផ្លូវទឹក និងធានាជំរុញការអភិវឌ្ឍវិស័យដឹកជញ្ជូនតាមផ្លូវទឹក ដើម្បីឲ្យមានការទុកចិត្តពីវិនិយោគិន ឲ្យដាក់ទុនវិនិយោគលើវិស័យដឹកជញ្ជូនតាមផ្លូវទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា[១]។



អង្គប្រជុំជាបន្តបន្ទាប់បានពិនិត្យពិភាក្សាលើសេចក្ដីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្ដីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ។

(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុរបស់សេចក្ដីព្រាងច្បាប់ស្ដីពីការដឹកជញ្ជូនតាមផ្លូវទឹក។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃព្រហស្បតិ៍ ទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង០៩:០០នាទីព្រឹក នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) ព្រមទាំងសមាជិក ECOSOCC ឯកឧត្តម **សយ សុខា** អគ្គលេខាធិការរាជរដ្ឋាភិបាល ក្រុមប្រឹក្សាអ្នកច្បាប់ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** ឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា(តំណាងសាមីក្រសួង) និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១- សេចក្ដីព្រាងច្បាប់ស្ដីពី យុត្តិធម៌អនីតិជន

២- បញ្ហាផ្សេងៗ។

យោងតាមសេចក្ដីថ្លែងហេតុស្ដីពីការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ដែលបានជម្រាបជូនអង្គប្រជុំ ដោយឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅមុនពេលចាប់ផ្ដើមពិនិត្យនិងពិភាក្សានោះ ក៏បានបង្ហាញឲ្យឃើញថា ការរៀបចំតាក់តែងនេះគឺត្រូវបានអនុលោមតាម៖





-អនុសាសន៍ដ៏ខ្ពង់ខ្ពស់ជាបន្តបន្ទាប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការលើកស្ទួយសិទ្ធិកុមារ

-កម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៥ របស់រាជរដ្ឋាភិបាលកម្ពុជា ចែងជាអាទិ៍ថា៖ រាជរដ្ឋាភិបាលប្តូរផ្តាច់ដាក់ចេញនូវវិធានការគ្រប់បែបយ៉ាងដើម្បីទប់ស្កាត់អំពើកៀបសង្កត់អំពើពេស្យាចារលើកុមារ ការជួញដូរកុមារ ការពង្រឹងការអនុវត្តច្បាប់ ការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌

**-មាត្រា៤៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ចែងថា៖ រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពី កុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឲ្យខូចការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឲ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

**-មាត្រា៤០ នៃបទដ្ឋានអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ និងពិធីសារបំពេញបន្ថែមចែងថា៖** រដ្ឋភាគីទទួលស្គាល់ថា កុមារដែលជាប់សង្ស័យ ជាប់ចោទ ឬដែលគេស្គាល់ថា បានល្មើសនឹងច្បាប់ព្រហ្មទណ្ឌ មានសិទ្ធិទទួលបាននូវការប្រព្រឹត្តមកលើខ្លួន តាមលក្ខណៈមួយដែលលើកស្ទួយសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់កុមារ ដែលពង្រឹងកុមារឲ្យចេះគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ ដោយគិតពីអាយុរបស់កុមារ ព្រមទាំងអត្ថប្រយោជន៍នៃការលើកស្ទួយ ការធ្វើសមាហរណកម្មកុមារមកក្នុងសង្គមជាតិ និងឲ្យកុមារបំពេញតួនាទីស្ថាបនាក្នុងសង្គម។

-ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះ មាន១៦ជំពូក និងចែកចេញជា ៨៩មាត្រា ហើយមានសារៈប្រយោជន៍សំខាន់ៗជាចម្បងគឺ៖

-ការពារសិទ្ធិនិងឧត្តមប្រយោជន៍របស់កុមារ ការពារផលប្រយោជន៍របស់ជនរងគ្រោះ សហគមន៍ និងសង្គម

-បង្កើននូវការអប់រំ ទប់ស្កាត់នូវភាពអសកម្មផ្សេងៗក្នុងជួរអនីតិជន ដែលឆ្លើយតបទៅនឹងវិធានការទាំងឡាយដែលរាជរដ្ឋាភិបាលរួមគ្នាជាមួយគ្រួសារ សហគមន៍ ដៃគូអភិវឌ្ឍ និងអង្គការ មិនមែនរដ្ឋាភិបាលនានា ដែលបាននិងកំពុងតែខិតខំក្នុងការអភិវឌ្ឍអនីតិជនឲ្យក្លាយជាពលរដ្ឋល្អ ជាអ្នកបន្តវេនរបស់ប្រទេសជាតិ

-បង្កើននូវកិច្ចសហការគ្នារវាងបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការនីតិប្រតិបត្តិ និងតុលាការ ក្នុងការដោះស្រាយបញ្ហាអនីតិជនឲ្យស្របទៅនឹងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធកុមារ

-បំពេញនូវកាតព្វកិច្ចជាប្រទេសសមាជិកនៃអនុសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

-បង្កើននូវកិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជាជាមួយនឹងបណ្តាស្ថាប័នអន្តរជាតិនានាក្នុងការការពារសិទ្ធិកុមារ។

ក្រោយពីបានពិនិត្យ និងពិភាក្សាគ្នាយ៉ាងផុសផុលរួចមក កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយនេះបានសម្រេចឯកភាពនូវលទ្ធផលដូចខាងក្រោម៖

**១-ចំពោះទម្រង់នៃសេចក្តីព្រាងច្បាប់នេះ** អង្គប្រជុំបានសម្រេចរក្សាទុកទម្រង់ដើមទាំងស្រុង

២-ចំពោះចំណងជើងនៃសេចក្តីព្រាងច្បាប់នេះ អង្គប្រជុំបានលើកគោលការណ៍ជាជម្រើសពីរ គឺទីមួយដាក់ថា **“ច្បាប់ស្តីពីយុត្តិធម៌អនីតិជន”** (តាមចំណងជើងដើម) និងទីពីរដាក់ថា **“ច្បាប់ស្តីពី ការការពារសិទ្ធិអនីតិជនដែលប្រព្រឹត្តល្មើស”** ដើម្បីដាក់ឆ្លងសុំមតិយោបល់សម្រេចដ៏ខ្ពង់ខ្ពស់ពី សម្តេចតេជោប្រមុខរាជរដ្ឋាភិបាលនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាពេលខាងមុខ។

៣-មាត្រា១៥ កថាខណ្ឌទី១ បន្ថែមឃ្លា **“រាល់ការចាប់ខ្លួនអនីតិជន ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម”** នៅខាងចុងកថាខណ្ឌ បន្ទាប់ពីសញ្ញាខណ្ឌ “។”

៤-មាត្រា១៧ កថាខណ្ឌទី១ បន្ថែមឃ្លា **“រាល់ការឃាត់ខ្លួនអនីតិជន ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម” នៅបន្ទាប់ពីប្រយោគ........បទមជ្ឈិមដោយចេតនា។”** ។

អង្គប្រជុំត្រួតពិនិត្យចុងក្រោយនេះបានបញ្ចប់នៅវេលាម៉ោង ១២:៣០នាទី នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយនិងស្និទ្ធស្នាលបំផុត៕

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកុម្ភៈ ឆ្នាំ២០១៦*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌កម្ពុជា **ប្រចាំខែកុម្ភៈ ឆ្នាំ២០១៦**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកុម្ភៈ ឆ្នាំ២០១៦ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ០៤%, ធៀបនឹងខែមុន និងកើនឡើង ២៣%, ធៀបនឹងខែដូចគ្នាឆ្នាំមុន ។(ខែ១២រយៈពេល)

តារាង១.១ .បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +៩៧,% | សាច់គោ: | +១០៤,% |
| ភោជនីយដ្ឋាន: | +៦៦%, | ត្រីស្រស់: | +៨៨%, |
| ម្ហូបអាហារ: | +៤៧%, | សាច់ជ្រូក: | +៥១%, |
| សំលៀកបំពាក់ និងស្បែកជើង: | ៣+,៧% | សាច់មាន់: | +៤៨%, |
| ការកំសាន្ត និងវប្បធម៌: | +៣% | ផ្លែឈើ: | +៣,៦% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +១៩,% | បន្លែ: | +៣% |
| សុខាភិបាល: | +១,៧% | | |

តារាង១.២បម្រែបម្រួល .សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៤–២០១៦

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា P | មេសា P | ឧសភា P | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២៣%, | ២៤%, | ២៤%, | ២៥%, | | | | | | | | |
| | មុន | ០-,២% | ០,៤% | ០២%, | ០៧%, | ០២%, | | | | | | | | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២៨,% | |
| | មុន | ០-,៤% | ១,២% | ០,១% | ០៧,% | ០១%, | ០២%, | ០៦%, | ០៣%, | ០២%, | ០% | -០,២% | ០,២% | |
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤៥%, | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤២%, | ៤១%, | ៣៦%, | ២៩%, | ២៤%, | ២៥%, | ៤០%, |
| | មុន | ០២,% | ០ | ០,៥% | ០,៥% | ០៣,% | ០៥,% | ០៤%, | ០៣%, | ០២%, | -០,៤% | -០,៨% | ០៧%, | |

**P :** តួលេខខែមិនា មេសា និងឧសភាឆ្នាំ២០១៦ ជាតួលេខព្យាករ តាមវិធីសាស្រ្ត )**DECOMPOSITION** )

* ការវិភាគជាសំណោរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | កុម្ភៈ២០១៦ | មករា២០១៦ | កុម្ភៈ២០១៥ | *ប្រភេទ* | កុម្ភៈ២០១៦ | មករា២០១៦ | កុម្ភៈ២០១៥ |
|---|---|---|---|---|---|---|---|
| **រ/ដុល្លារ** | ៤០០៨រ/១$ | ៤០៣៧រ/១$ | ៤០២៧រ/១$ | **បាត/ដុល្លារ** | ៣៥,៧៣បាត/១$ | ៣៥,៨៣បាត/១$ | ៣២,៣៧បាត/១$ |
| **រ/បាត** | ១១២រ/១បាត | ១១៣រ/១បាត | ១២៤រ/១បាត | **ដុង/ដុល្លារ** | ២២២៩៣ដុង/១$ | ២២១៩៣ដុង/១$ | ២១៣៣៥ដុង/១$ |
| **រ/ដុង** | ០,១៨០រ/១ដុង | ០,១៨២រ/១ដុង | ០,១៨៩រ/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែកុម្ភៈឆ្នាំ២០១៦ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១.ចំណូលថវិកាជាតិ**:អនុវត្តបាន១០៥០,១ប៊ីលានរៀល (*មធ្យមប្រចាំខែ ៨៣% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន ១០៤១,២ប៊ីលានរៀល(*មធ្យមប្រចាំខែ ៨៥% នៃផែនការ*) និងចំណូលមូលធនមាន៨,៩ប៊ីលានរៀល (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៤-២០១៦ (ប៊ីលានរៀល)




➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង២២,៧% និងកើនឡើង ៤៦,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ៩៥៧,៣ប៊ីលានរៀល កើនឡើង២០,២%ធៀបនឹងខែមុន និងកើនឡើង៣៩,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខរតនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន ៨៣,៩ប៊ីលានរៀល កើនឡើង ៤០,៦% ធៀបនឹងខែមុន និងកើនឡើង ១៩៦,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខរតនាគារជាតិ)។

តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ (ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ(តាមតួលេខ រតនាគារជាតិ) (ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: -៥,៦% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+២៥,៥%) | ➢ នេសាទ:+៤,៥% | (-៦២,៣%) |
| | | ➢រុក្ខាប្រមាញ់: | ( ) |
| ➢ ចំណូលពន្ធដារ: -០,៧% (អគ្គនាយកដ្ឋានពន្ធដារ) | (+១៩,៨%) | ➢សម្បទានរ៉ែ: - | (+២៥៧,៧%) |
| | | ➢ អាកាសចរណ៍ស៊ីវិល:+៧១២,១% | (+១០,៤%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ:+ (តាមតួលេខ រតនាគារជាតិ) | (-) | ➢ផលទុននៃសកម្មភាពទេសចរណ៍: +៣១៩,៣% | (+៣៧៥,១%) |
| | | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍: -៨៨,២% | (-៨៦,៩%) |
| ✧ កាស៊ីណូ :-២៩% | +១៣,៤%) | ➢អាករស្នាក់នៅ(លិខិតឆ្លងដែននិងទិដ្ឋាការ):-៣,៨% | (+១២៨៨,៨%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +២៩៦,៦% | (-៤៩,៩%) | ➢ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ: | |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ :+ | (-) | | |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ៦៥១,៣ប៊ីលានរៀល( *មធ្យមប្រចាំខែ ៥៦% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន ៤៧០ប៊ីលានរៀល (*មធ្យមប្រចាំខែ ៥៥% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១៨១,៣ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង ៤% ធៀបនឹងខែមុននិងកើនឡើង២,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ១៥,១% ធៀបនឹងខែមុននិងថយចុះ១០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៤-២០១៦ (ប៊ីលានរៀល)




**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះ មានអតិរេកចំនួន **៣៩៨,៨**ប៊ីលានរៀល (តាមតួលេខ រតនាគារជាតិ)។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកុម្ភៈឆ្នាំ២០១៦មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ$M_2$ មានចំនួន ៥០០៣៧ប៊ីលានរៀល កើនឡើង០,៩% ធៀបនឹងខែមុន និងកើនឡើង ១៥,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង $M_2$** ក្នុងខែនេះ ជារួម បណ្ដាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ ០,៣% ប្រាក់បញ្ញើមានការកំណត់ និងសន្សំ០,៤% និងប្រាក់បញ្ញើជារូបិយបណ្ណ ១,១%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកុម្ភៈឆ្នាំ២០១៦



➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន ១៦,៦% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣,៤% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៦

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៦,៨% | ១៦,៦% | | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១២,២% | ១២,១% | | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែកុម្ភៈ២០១៦: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




---

➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៥០៩៦លានដុល្លារ កើនឡើង២% ធៀបនឹងខែមុន និងកើនឡើង១៥,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១៥៧២០ ប៊ីលានរៀល ថយចុះ២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៣,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *កុម្ភៈ២០១៦* | *មករា២០១៦* | *កុម្ភៈ២០១៥* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ៥០៤៨៩ | ៤៩៩៤៣ | ៣៩៧៧៦ |
| ក្នុងនោះ: ជារៀល | | | ៤៨៦ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១២៦៤៣ | ៨៨១៥ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៦២% | ៦,៦២% | ៦,៧៩% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,៣១% | ១៦,៣១% | ១៦,១៣% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៦% | ៤,៤៦% | ៤,២៩% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៦៧% | ១១,៨២% | ១១,៦៦% |

### ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែកុម្ភៈឆ្នាំ២០១៦ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៤៨,១ពាន់តោន កើនឡើង២% ធៀបនឹងខែមុន ប៉ុន្តែថយចុះ១៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ **រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៥០៥,២៣GWH មានការថយចុះ៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ៣៩,៧៥GWH មានការថយចុះ៣១% ធៀបនឹងខែមុន និងថយចុះ៤០% ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន២៧០,៧GWH មានការថយចុះតិចតួចធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង៥១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ **ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៥០៤,៤លានដុល្លារ មានការថយចុះ២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –កុម្ភៈ២០១៦ | ចំនួន–មករា២០១៦ | ចំនួន–កុម្ភៈ២០១៥ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១២ | ១៤ | ៩ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៤៧៦ | ១៤៦៤ | ១៣១៥ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | — | — | — |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | — | — | — |

➢ **សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៨៧២,១ពាន់ម$^{២}$ កើនឡើង២៦% ធៀបនឹងខែមុន និងកើនឡើង៣៥៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៥០៩,១លានដុល្លារកើនឡើង៣០% ធៀបនឹងខែមុន និងកើនឡើង៨៦៤% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម$^{២}$ –កុម្ភៈ២០១៦ | ពាន់ម$^{២}$ –មករា២០១៦ | ពាន់ម$^{២}$ –កុម្ភៈ២០១៥ |
|---|---|---|---|
| ▪ លំនៅឋាន | ៦១៣,៨ | ២៧៨,៨ | ៤៩,៧ |
| ▪ ឧស្សាហកម្ម | ១៤២,៥ | ១២៥,២ | ១២៥,៧ |
| ▪ពាណិជ្ជកម្ម | ១០៣,១ | ២៧៩ | ៣,២ |
| ▪ ទេសចរណ៍ | ៤,៥ | ៧,៩ | ៦,៧ |
| ▪ផ្សេងៗ | ១,៣ | ០,០ | ៣,១ |
| អនុញ្ញាតសរុប | ៨៧២,១ | ៦៩៣,៥ | ១៩២ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅដ្ឋាន៧០,៤% និងឧស្សាហកម្ម១៦,៣% នៃផ្ទៃក្រឡាសរុប។

➢ **ការងារ**

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–កុម្ភៈ២០១៦ | នាក់–មករា២០១៦ | នាក់–កុម្ភៈ២០១៥ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ ) | ៤៤១ | ៧៣៧ | ១០២២ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៣៥៨៧ | ៥៨៦៦ | ៧៤៤៥ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១១២៣៤ | ៤៧៨០ | ៦០៣១ |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៣៥៣ | ១០៨៦ | ១៤១៤ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កុម្ភៈ២០១៦ | មករា២០១៦ | កុម្ភៈ២០១៥ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៧៩៨,៩ | ១៦៨,៥ | ៣៥,៧ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៣៨,៣ | ២,២ | ០,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៤៧,៧ (១,៦) | ៩៦.៩ (៣៨,៦) | ៣៥,៧ (៨,៩) |
| វិស័យទេសចរណ៍ | ៥៧៣ | ៦៩,៤ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១៤០ | ០,០ | ០,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២០ | ១៦ | ១២ |
| បង្កើតការងារ (ពាន់នាក់) | ២២,១ | ១០,៧ | ១៣,៤ |

## ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន—កុម្ភៈ២០១៦ | ចំនួន—មករា២០១៦ | ចំនួន—កុម្ភៈ២០១៥ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | | | ៣៥៥ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | | | ៥ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៧៩៦ | ១៣៦ | ២១០ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៦៩៨,៦ពាន់តោន ថយចុះ១៨% ធៀបនឹងខែមុន និង ថយចុះ៨% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-១៨% | (-១%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:-១៦% | (-២៨%) |
| ▪ កំពង់ផែកំពង់សោម:-២៣% | (-៦%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +៩៤% | (-២២%) |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១២,៨ | -១៧% | ៨% |
| ក្នុងនោះទទួល | ២,២ | -២% | ២០% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១២៥,៨ | ៤% | ៤% |
| ក្នុងនោះទទួល | ៤៨,៤ | -៧% | ២២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៨៥៩,៩ | -៧% | -១៥% |
| ក្នុងនោះហៅចូល | ៨៣០,៧ | -៨% | -១០% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១១៨៩៧,៩ | -២២% | ២៩% |
| ក្នុងនោះហៅចូល | ១១៨៤៣,៨ | -២២% | ៣០% |

### ➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២១,៩ | ៥៦% | -៣% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤៧,៩ | ១២% | ៥% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៥៩១,៨ | –៣% | ៩% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | | | |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា<br>✓ តាមផ្លូវអាកាស<br>✓ តាមផ្លូវគោក និងទឹក | | | |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែកុម្ភៈមានចំនួន ៤០៣៣,៣ប៊ីលានរៀល (ស្មើនឹង ១០០៨,៣លានដុល្លារ ស.រ.អា.) ថយចុះ៤% ធៀបនឹងខែមុននិងថយចុះ១,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -២,៣% | +៧,៩% | រថយន្តសរុប (ប៊ី.ល.រ) | +២០,១% | +៥៤,២% |
| ប្រេងម៉ាស៊ូត | -៧,៣% | +៩,៥% | រថយន្តសរុប (គ្រឿង) | -០,៥% | +៩៤,២% |
| ឧស្ម័ន | +០,៧% | +១១,២% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៥១,២% | -១៨,១% |
| អគ្គិសនីនាំចូល | -៥% | -៧% | ម៉ូតូ (គ្រឿង) | -៣% | +២២,៣% |
| ដែកសំណង់ | -២៨,៩% | +៨២,២% | អង្ករ | +៣២,៣% | -៥៤,៨% |
| ស៊ីម៉ង់ត៍ | -២,៥% | -៣៩,១% | ផ្លែឈើនិងបន្លែ | -២៣,៧% | -៣៥,៥% |
| គ្រឿងអេឡិចត្រូនិក | -២៨,៦% | +២៩,២% | ជីនិងថ្នាំកសិកម្ម | -៦៩,៧% | -១៦,៤% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -២៥,៨% | -១៧,៨% |

➡ **ការនាំចេញ** ខែកុម្ភៈឆ្នាំ២០១៦ មានចំនួន**៣០៥១,២**ប៊ីលានរៀល ស្មើនឹង**៧៦២**,៨លានដុល្លារ ស.រ.អា. (**៧៥**,៦% នៃការនាំចូល)ថយចុះ១០,៧% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៥,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៤៣,៧% | -៦៣,៨% | ផលិតផលនេសាទ | +១២,៩% | -៧៧,២% |
| វាយនភណ្ឌនិងស្បែកជើង | -១១,៧% | +១៥,៦% | កៅស៊ូ | -៤៤% | -៩,២% |
| អង្ករ | -៩,៣% | +២៥,៤% | | | |

➡ក្នុងខែកុម្ភៈនេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៩៨២,២ប៊ីលានរៀលស្មើនឹង២៤៥,៥លានដុល្លារ ស.រ.អា.។



## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកុម្ភៈឆ្នាំ២០១៦នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់គោស្រស់ | +១,៦% | +១០,៤% | — |
| | ផលិតកម្មនេសាទ | +២% | -១៥% | — |
| ៣ | ទំនិញដឹកជញ្ជូនតាមផែ | -១៨% | -៨% | — |
| ៤ | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -២៥,៨% | -១៧,៨% | ជាតួលេខនាំចូលវត្ថុធាតុដើម |

## ៧) សេចក្ដីសន្និដ្ឋាន

១) អង្គប្រជុំបានចាប់អារម្មណ៍លើការតម្លើងថ្លៃបង់ការសិក្សានៅថ្នាក់ឧត្តមសិក្សា ដែលបញ្ហានេះ រាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានដោះស្រាយរួចហើយ តាមរយៈសេចក្ដីបំភ្លឺលេខ ៥០០៣ អពដ របស់អគ្គនាយកដ្ឋានពន្ធដារ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦។

២) អង្គប្រជុំបានចាប់អារម្មណ៍លើកិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដែលកំពុងធ្វើកំណែទម្រង់សេវាសុខាភិបាលឲ្យកាន់តែប្រសើរជាងមុន។ ការថយចុះនូវគុណភាពសេវាសុខាភិបាល នឹងនាំឲ្យសេដ្ឋកិច្ចបាត់បង់ចំណូលយ៉ាងច្រើន។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា
## ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៦

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០២/១៦<br>ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំលេខាធិការដ្ឋាននៃអាកាសយានដ្ឋានព្រលានយន្តហោះនៅកម្ពុជា នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៥/០២/១៦<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលពាណិជ្ជកម្មកោះពេជ្រ។ |
| ៣ | ០៧/០២/១៦<br>ម៉ោង១១:៣០នាទី | ចូលរួមជួបពិភាក្សាការងារជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅគេហដ្ឋាន ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ |
| ៤ | ០៩/០២/១៦<br>ម៉ោង០៩:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងច្បាប់ ស្ដីពីយុត្តិធម៌អនីតិជន<br>២-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១១/០២/១៦<br>ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្ដីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំឆ្នាំ២០១៥ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១២/០២/១៦<br>ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ១៨/០២/១៦<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែមករា ឆ្នាំ២០១៦ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១៨/០២/១៦<br>ម៉ោង១៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងកម្មវិធី Cambodia-Kizuna ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅវិទ្យាស្ថានភាសាបរទេស។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម ឃឹម ណុលឡា
## ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៦ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | ២៣/០២/១៦<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំ៦ នៃស្រុកព្រៃកប្បាស នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ២៥/០២/១៦<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធ "អគារមរតកតេជោ" ក្រសួងបរិស្ថាន និងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៥ និងទិសដៅការងារឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅទីស្តីការក្រសួងបរិស្ថានថ្មី។ |
| ១១ | ២៦/០២/១៦<br>ម៉ោង១១:០០នាទី | អនុញ្ញាតឲ្យក្រុមអ្នកចតរីដេអូនៃក្រុមហ៊ុន VINCI Airports ចូលជួបធ្វើបទសម្ភាស នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ២៦/០២/១៦<br>ម៉ោង១៤:០០នាទី | ចូលរួមជាកិត្តិយស ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥ និងផែនការសកម្មភាពការងារឆ្នាំ២០១៦ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៣ | ២៩/០២/១៦<br>ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ម៉ិច សុខា** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in